# វីរុសបង្កឱ្យមានជំងឺផ្លូវដង្ហើម (RSV) អង្គបដិប្រាណបង្ការជំងឺ៖

*អ្វីដែលអ្នកត្រូវដឹង*

## ហេតុអ្វីត្រូវចាក់ថ្នាំបង្ការអង្គបដិប្រាណបង្ការជំងឺ RSV?

អង្គបដិប្រាណបង្ការនៃវីរុសបង្កឱ្យមានជំងឺផ្លូវដង្ហើម (Respiratory Syncytial Virus, RSV) អាចបង្ការជំងឺសួតធ្ងន់ធ្ងរដែលបណ្តាលមកពីវីរុស RSV ។

RSV គឺជាមេរោគផ្លូវដង្ហើមទូទៅមួយ ដែលជាញឹកញាប់បណ្តាលឱ្យមានរោគសញ្ញាស្រាល និងដូចជាផ្តាសាយ ប៉ុន្តែក៏អាចប៉ះពាល់ដល់សួតផងដែរ។ រោគសញ្ញានៃការឆ្លងមេរោគ RSV អាចរួមមានការហៀរសំបោរ  ការថយចុះនៃចំណង់បរិភោគ ការក្អក ការកណ្តាស់ គ្រុនក្តៅ ឬដកដង្ហើមក្រឹតក្រត។។

នរណាក៏អាចឆ្លងមេរោគ RSV បានដែរ ហើយកុមារស្ទើរតែទាំងអស់ឆ្លងមេរោគ RSV នៅពេលពួកគេមានអាយុ 2 ឆ្នាំ។ ទោះបីជាកុមារភាគច្រើនជាសះស្បើយពីការឆ្លងមេរោគ RSV ក្នុងមួយសប្តាហ៍ ឬពីរសប្តាហ៍ក៏ដោយ ក៏ការឆ្លងមេរោគ RSV អាចបង្កគ្រោះថ្នាក់ដល់ទារក និងកុមារតូចៗមួយចំនួន ដែលបណ្តាលឱ្យពិបាកដកដង្ហើម មានកម្រិតអុកស៊ីសែនទាប និងការខ្វះជាតិទឹក។ នៅសហរដ្ឋអាមេរិក RSV គឺជាមូលហេតុទូទៅបំផុតនៃជំងឺរលាកទងសួត (ការរលាកផ្លូវដង្ហើមតូចនៅក្នុងសួត) និងជំងឺហើមសួត (ការឆ្លងមេរោគទៅសួត) ចំពោះកុមារអាយុក្រោម 1 ឆ្នាំ។ កុមារដែលឈឺដោយសារវីរុស RSV ប្រហែលជាត្រូវសម្រាកនៅមន្ទីរពេទ្យ ហើយកុមារខ្លះអាចស្លាប់។

## អង្គបដិប្រាណបង្ការជំងឺ RSV

អង្គបដិប្រាណបង្ការជំងឺ RSV (ឈ្មោះទូទៅ Nirsevimab ឈ្មោះពាណិជ្ជកម្ម Beyfortus) គឺជាថ្នាំចាក់ដែលបង្ការជំងឺ RSV ធ្ងន់ធ្ងរចំពោះទារក និងកុមារតូចៗ។ អង្គបដិប្រាណគឺជាប្រូតេអ៊ីនដែលប្រព័ន្ធភាពស៊ាំរបស់រាងកាយប្រើប្រាស់ ដើម្បីប្រឆាំងនឹងមេរោគដែលបង្កគ្រោះថ្នាក់។ ដូចជាវ៉ាក់សាំងប្រពៃណីដែរ អង្គបដិប្រាណបង្ការជំងឺគឺជាការចាក់ថ្នាំបង្ការដែលផ្តល់ការការពារប្រឆាំងនឹងមេរោគជាក់លាក់មួយ។ ទោះវ៉ាក់សាំងទាំងពីរប្រភេទ គឺជាការចាក់ថ្នាំបង្ការជំងឺក៏ដោយ ក៏វិធីដែលវាផ្តល់ភាពស៊ាំគឺខុសគ្នា។ Nirsevimab គឺជាការចាក់ថ្នាំបង្ការដែលផ្តល់អង្គបដិប្រាណដោយផ្ទាល់ដល់អ្នកទទួល។ វ៉ាក់សាំងប្រពៃណីគឺជាការចាក់ថ្នាំបង្ការដែលជំរុញប្រព័ន្ធភាពស៊ាំរបស់អ្នកទទួលដើម្បីបង្កើតអង្គបដិប្រាណ។

ទារកដែលកើតក្នុងរដូវមានជំងឺ RSV (ជាធម្មតាពីរដូវស្លឹកឈើជ្រុះដល់រដូវផ្ការីក) គួរតែទទួលបានការចាក់វ៉ាក់សាំង RSV មួយដូសក្នុងរយៈពេល 1 សប្តាហ៍បន្ទាប់ពីកំណើត។ ទារកភាគច្រើនដែលម្តាយបានទទួលវ៉ាក់សាំង RSV មិនចាំបាច់ត្រូវទទួលវ៉ាក់សាំង Nirsevimab ដែរទេ។ វ៉ាក់សាំងទាំងពីរបង្ការទារកពីជំងឺ RSV ធ្ងន់ធ្ងរ ដោយផ្តល់អង្គបដិប្រាណ ពីម្តាយទៅទារក ឬដោយផ្ទាល់ដល់ទារក។ ទារកភាគច្រើនទំនងជាគ្រាន់តែត្រូវមានការការពារពីវ៉ាក់សាំង RSV របស់ម្តាយ ឬ Nirsevimab តែប៉ុណ្ណោះ (មិនមែនត្រូវការទាំងពីរទេ)។ ទោះយ៉ាងណាក៏ដោយ វាអាចមានស្ថានភាពមួយចំនួនដែល Nirsevimab នឹងត្រូវបានណែនាំឲ្យប្រើសម្រាប់ទារក បន្ទាប់ពីម្តាយបានទទួលវ៉ាក់សាំង RSV ។

ទារកដែលកើតនៅក្រៅរដូវឆ្លងជំងឺ RSV ដែលកុមារមានអាយុក្មេងជាង 8 ខែ គួរតែទទួលបានការចាក់ថ្នាំបង្ការជំងឺ RSV មួយដូសភ្លាមៗ មុនពេលរដូវឆ្លងជំងឺ RSV ដំបូងរបស់ពួកគេ (ជាទូទៅគឺរដូវស្លឹកឈើជ្រុះ) ប៉ុន្តែទារកដែលមានអាយុតិចជាង 8 ខែដែលមិនទាន់បានទទួលថ្នាំអាចទទួលបានដូចថ្នាំនៅពេលណាក៏បាននៅក្នុងរដូវនេះ។

ទារក និងកុមារតូចៗមួយចំនួនដែលមានហានិភ័យខ្ពស់ចំពោះជំងឺ RSV ធ្ងន់ធ្ងរអាចត្រូវការអង្គបដិប្រាណ RSV តែមួយដូស នៅមុន ឬនៅអំឡុងពេលរដូវជំងឺ RSV ទីពីររបស់ពួកគេ។

អង្គបដិប្រាណបង្ការជំងឺ RSV អាចត្រូវបានផ្តល់ឱ្យក្នុងពេលដំណាលគ្នាជាមួយនឹងវ៉ាក់សាំងដែលត្រូវបានណែនាំឲ្យប្រើប្រាស់ជាប្រចាំសម្រាប់ទារក និងកុមារតូចៗ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## សូមនិយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក

សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកទទួលអង្គបដិប្រាណបង្ការជំងឺមាន៖

- ប្រវត្តិនៃប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរចំពោះអង្គបដិប្រាណបង្ការជំងឺ RSV (Nirsevimab) ឬសមាសធាតុណាមួយរបស់វ៉ាក់សាំងនេះ
- ជំងឺហូរឈាម ឬ
- ជំងឺស្រួចស្រាវកម្រិតមធ្យម ឬធ្ងន់ធ្ងរ។

ក្នុងករណីខ្លះ អ្នកផ្តល់សេវាថែទាំសុខភាពរបស់កូនអ្នកអាចសម្រេចចិត្តពន្យារពេលចាក់វ៉ាក់សាំងបង្ការជំងឺ RSV រហូតដល់ការទៅជួបនាពេលខាងមុខ។

អ្នកដែលមានជំងឺតិចតួច ដូចជាផ្តាសាយ អាចទទួលបានអង់ទីករបង្ការជំងឺ RSV ដោយសុវត្ថិភាព។ អ្នកដែលមានជំងឺមធ្យម ឬធ្ងន់ធ្ងរ គួររង់ចាំ រហូតដល់ពួកគេជាសះស្បើយសិន។

អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់អ្នកបាន។

## ហានិភ័យនៃប្រតិកម្មទៅនឹងអង្គបដិប្រាណបង្ការជំងឺ RSV

បន្ទាប់ពីទទួលបានអង្គបដិប្រាណបង្ការជំងឺ RSV កូនរបស់អ្នកអាចមានការឈឺចាប់បណ្តោះអាសន្ន ការឡើងក្រហម ការហើមនៅកន្លែងចាក់ ឬរោលកន្ទួល។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងបង្ការជំងឺ RSV អាចមានដោយកម្រនូវប្រតិកម្មអាលែហ្ស៊ីធ្ងន់ធ្ងរ របួសធ្ងន់ធ្ងរផ្សេង ឬធ្វើឲ្យស្លាប់។

ប្រតិកម្មអាលែហ្ស៊ីអាចកើតឡើងបន្ទាប់ពីកូនរបស់អ្នកចាកចេញពីមន្ទីរពេទ្យ ឬគ្លីនិក។ ប្រសិនបើអ្នកឃើញសញ្ញានៃប្រតិកម្មអាឡែហ្ស៊ីធ្ងន់ធ្ងរ (ឧទាហរណ៍ កន្ទួលកហម ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម បេះដូងលោតញាប់ វិលមុខ ឬខ្សោយ) សូមទូរស័ព្ទទៅ 9-1-1 ហើយនាំកូនអ្នកទៅមន្ទីរពេទ្យដែលនៅជិតបំផុត។

ទូរសព្ទទៅអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកឃើញរោគសញ្ញាផ្សេងទៀតដែលអ្នកព្រួយបារម្ភ។

## ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

ប្រសិនបើកូនរបស់អ្នកទទួលបានអង្គបដិប្រាណបង្ការជំងឺ RSV ដោយមិនបានចាក់វ៉ាក់សាំងក្នុងពេលតែមួយ ហើយអ្នកសង្ស័យថាមានប្រតិកម្មមិនល្អ អ្នក ឬអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចដាក់របាយការណ៍តាមរយៈ https://www.fda.gov/medwatch ឬតាមទូរស័ព្ទមកលេខ 1-800-FDA-1088។

ប្រសិនបើកូនរបស់អ្នកទទួលបានអង្គបដិប្រាណបង្ការជំងឺ RSV និងវ៉ាក់សាំងក្នុងពេលតែមួយ ហើយអ្នកសង្ស័យថាមានប្រតិកម្មមិនល្អ អ្នក ឬអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកគួររាយការណ៍វាទៅប្រព័ន្ធរាយការណ៍ព្រឹត្តិការណ៍អាក្រក់កើតចេញវ៉ាក់សាំង (Vaccine Adverse Event Reporting System, VAERS) https://vaers.hhs.gov/ ឬទូរស័ព្ទទៅ 1-800-822-7967។ នៅក្នុងរបាយការណ៍របស់អ្នក សូមកត់សម្គាល់ថា កូនរបស់អ្នកបានទទួលការចាក់ថ្នាំបង្ការ RSV ព្រមជាមួយនឹងវ៉ាក់សាំង។

សម្គាល់៖ MedWatch និង VAERS គឺសម្រាប់តែរាយការណ៍អំពីប្រតិកម្មតែប៉ុណ្ណោះ។ សមាជិកបុគ្គលិក MedWatch និង VAERS មិនផ្តល់ដំបូន្មានផ្នែកវេជ្ជសាស្ត្រទេ។

## តើខ្ញុំអាចស្វែងយល់បន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅតាមមូលដ្ឋានរបស់អ្នក។
- ចូលទៅកាន់គេហទំព័ររដ្ឋបាលចំណីអាហារ និងឱសថរបស់សហរដ្ឋអាមេរិកនៅ Drugs@FDA៖ ឱសថដែលត្រូវបានអនុម័តដោយ FDA (Food and Drug Administration)។
- សូមទាក់ទងមជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រង និងទប់ស្កាត់ជំងឺ (Centers for Disease Control and Prevention, CDC)៖
  - ទូរស័ព្ទទៅលេខ 1-800-232-4636 (1-800-CDC-INFO) ឬ
  - ចូលទៅកាន់គេហទំព័រ CDC https://www.cdc.gov/rsv/about/prevention.html

Khmer translation provided by Immunize.org